

ព័ត៌មានបន្ថែម អំពីគម្រោងសាលាក្រុង ដើម្បីអនុវត្តតាមច្បាប់ជនពិការ និងជាពិសេសបណ្ដឹង និងសំណើពាក់ព័ន្ធនឹងកម្មវិធីសុំការសម្រួលផ្លូវធ្វើដំណើរ ដើម្បីដោះស្រាយកន្លែងថ្មើរជើង/សិទ្ធិអាទិភាពជាសាធារណៈ ដែលជនពិការ ឬអ្នកមើលថែគាត់ដាក់ប្ដឹង អាចរកបាននៅ៖

**longbeach.gov/citymanager/ada**

ដើម្បីរាយការណ៍អំពីទីតាំង ដែលមានបញ្ហាសម្រាប់បងប្អូនពិការ ពាក់ព័ន្ធនឹងសិទ្ធិផ្លូវអាទិភាព សូមទាក់ទងមន្ត្រីសម្របសម្រួលផ្នែកជនពិការរបស់សាលាក្រុង តាម៖ (562) 570-6257។

បើបងប្អូនត្រូវការព័ត៌មាននេះ ជាទម្រង់ផ្សេង សូមទូរស័ព្ទទៅមន្ត្រីសម្របសម្រួលផ្នែកជនពិការរបស់សាលាក្រុង តាមលេខនេះ **(562) 570-6257** ឬ អ៊ីម៉េល **jennifer.kumiyama@longbeach.gov**.

បងប្អូនក៏អាចរកព័ត៌មាននេះបានជាភាសាអេស្ប៉ាញ ខ្មែរ ឬតាហ្គាឡុក នៅទីនេះ៖ **longbeach.gov/citymanager/ada**.


**City of Long Beach Public Works**
411 W. Ocean Blvd.
Long Beach, CA 90802

**ទូរស័ព្ទ៖** (562) 570-5000

longbeach.gov/pw/

@LBPublicWorks


# កម្មវិធីជម្រាលគែមផ្លូវនៃច្បាប់ស្ដីពីជនពិការអាមេរិក

## ខិត្តប័ណ្ណអំពីជម្រាលគែមផ្លូវ សម្រាប់ជនពិការក្រុងឡុងប៊ិច



CITY OF LONG BEACH

ច្បាប់ស្តីពីជនពិការអាមេរិក គឺជាច្បាប់ស្តីពីសិទ្ធិពលរដ្ឋ ដែលហាមប្រាមការរើសអើងលើបុគ្គលទាំងឡាយណា ដែលមានពិការភាព នៅគ្រប់ទីកន្លែងសាធារណៈ ដើម្បីធ្វើយ៉ាងណា ឲ្យពួកគាត់មានសិទ្ធិដូចគ្នា និងមានឱកាសដូចគ្នានឹងមនុស្សដទៃទៀត។

នៅឆ្នាំ ២០១៤ មានបណ្តឹងមួយចោទប្រកាន់សាលាក្រុងឡុងប៊ិច ថាបានផ្តល់សេវាសម្រួលការធ្វើដំណើរមិនគ្រប់គ្រាន់ នៅលើចិញ្ចើមផ្លូវ កន្លែងដើរឆ្លងផ្លូវ ជម្រាលគែមផ្លូវ ផ្លូវដើរ និងកន្លែងថ្មើរជើង និងសិទ្ធិអាទិភាពដទៃទៀត សម្រាប់ជនដែលមានពិការភាព។ សាលាក្រុងឡុងប៊ិច មានអាណត្តិតាមច្បាប់ និងកិច្ចព្រមព្រៀងដំណោះស្រាយសម្រាប់ជនពិការ ដើម្បីផ្តល់សេវាទាំងនេះ ឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។ វាជារឿងសំខាន់បំផុតដែលរាល់ភាគីពាក់ព័ន្ធរបស់សាលាក្រុង ត្រូវទទួលស្គាល់ អំពីសារសំខាន់នៃកាតព្វកិច្ចទាំងនេះ។ ការខកខានមិនបានដោះស្រាយតាមសំណូមពរ អាចនាំឲ្យមានបណ្តឹងកាន់តែច្រើន និងការពិន័យជាប្រាក់ថែមទៀតផង។

ក្នុងខែ តុលា ឆ្នាំ ២០១៧ មានដំណោះស្រាយមួយផ្នែកនៃកិច្ចព្រមព្រៀងដំណោះស្រាយលើបញ្ហាជនពិការនេះ៖

១) ធ្វើជម្រាលគែមផ្លូវចំនួន ៤,៥០០ កន្លែង នៅតាមទីតាំងដែលមិនដែលមានពីមុន

២) ជួសជុលបន្ថែមជម្រាលគែមផ្លូវ ១៦,000 កន្លែង ឬចំណាយថវិកាអស់ ៥០ដុល្លារ ទៅលើជម្រាលគែមផ្លូវដែលមានស្រាប់តែមិនត្រូវស្តង់ដា

៣) ចំណាយថវិកា ១២៥លានដុល្លារ កែកន្លែងផ្លូវដើរផ្សេងៗទៀត ដែលមិនត្រូវស្តង់ដា មិនមែនតែជម្រាលគែមផ្លូវ ដូចជាចិញ្ចើមផ្លូវ និងកន្លែងដើរឆ្លងផ្លូវ

## តើកន្លែងណាខ្លះដែលតម្រូវឲ្យមានជម្រាលគែមផ្លូវ?

ជាទូទៅ ជម្រាលគែមផ្លូវ ត្រូវតែមានឲ្យ នៅទីណាដែលមានចិញ្ចើមផ្លូវឆ្លងកាត់គែមផ្លូវ។ ជម្រាលគែមផ្លូវត្រូវតែដំឡើង ដើម្បីធ្វើយ៉ាងណា អ្នកដែលពិការអាចធ្វើដំណើរ ដំណើរពីចិញ្ចើមថ្នល់ម្ខាង ឬតាមគែមផ្លូវណាក៏ដោយ ទៅកាន់ចិញ្ចើមផ្លូវម្ខាងទៀត។ នៅកន្លែងដែលមានជម្រាលគែមផ្លូវម្ខាងត្រូវតែមានម្ខាងទៀតនៃផ្លូវ ដើម្បីធ្វើយ៉ាងណាឲ្យជនពិការ អាចធ្វើដំណើរឆ្លងផ្លូវពីម្ខាងទៅម្ខាងទៀត។ នេះមានន័យថា ជម្រាលគែមផ្លូវនេះត្រូវតែមានយ៉ាងហោចណាស់ពីរ នៅគ្រប់ផ្លូវប្រសព្វសម្រាប់ជនពិការ ដើម្បីឲ្យពួកគាត់ធ្វើដំណើរឆ្លងកាត់ផ្លូវបានដោយប្រសិទ្ធភាព។

## តើហេតុអ្វី បានជាត្រូវជ្រើសរើសទីតាំងជាក់លាក់មួយ សម្រាប់ជម្រាលផ្លូវ?

ដើម្បីឲ្យស្របតាមលក្ខខណ្ឌនៃច្បាប់ស្តីពីជនពិការរបស់អាមេរិក ជម្រាលគែមផ្លូវត្រូវតែដាក់ឲ្យមានសម្រាប់កន្លែងដែលមានចិញ្ចើមផ្លូវស្រាប់ នៅតាមអគារសាធារណៈ តំបន់ដែលមានអ្នកថ្មើរជើងច្រើន កន្លែងដែលមានរថយន្តបើកបរច្រើន ឬបើកបរក្នុងល្បឿនលឿន កន្លែងដែលមានស្លាកសញ្ញាបញ្ជាសុវត្ថិភាពផ្លូវអាទិភាព (ឧទាហរណ៍ កន្លែងប្រព័ន្ធទឹកភ្លើង ប្រព័ន្ធបង្ហូរទឹក ដើមឈើធំៗ ផ្លូវរថយន្តក្រុង ។ល។)។





## តើហេតុអ្វី បានជាគែមផ្លូវត្រូវលាបពណ៌ក្រហម នៅផ្លូវប្រសព្វ?

ផ្នែក 10.22.060 នៃក្រមរបស់សាលាក្រុងឡុងប៊ិច ហាមចតយានយន្ត នៅចម្ងាយ ២០ហ្វីតទៅរកផ្លូវប្រសព្វ និង ១០ហ្វីត ពីចំណុចចេញពីផ្លូវប្រសព្វ ដើម្បីកុំឲ្យមានអ្វីនៅបាំង និងការពារសុវត្ថិភាព ក្នុងករណីមើលគ្នាមិនឃើញ។

## តើផ្លូវឡានចូលផ្ទះ ចាត់ទុកថាជាកន្លែង សម្រាប់អ្នកថ្មើរជើងដើរបាន ឬទេ?

ទេ! ដោយសារតែវាបង្ករគ្រោះថ្នាក់ផ្នែកសុវត្ថិភាព ដោយថាហេតុ រវាងអ្នកថ្មើរជើង និងយានយន្ត និងមិនត្រូវស្តង់ដាច្បាប់ និងលក្ខខណ្ឌសម្រាប់ជម្រាលគែមផ្លូវ ។

## តើហេតុអ្វី បានជាការកែលម្អទីតាំងចំណត និងចំណីផ្លូវជាប់ចិញ្ចើមផ្លូវត្រូវប្តូរទៅកន្លែងផ្សេង?

សាលាក្រុងខិតខំកាត់បន្ថយផលប៉ះពាល់ដល់ការចតយានយន្ត និងផលប៉ះពាល់ដល់ចំណីផ្លូវជាប់ចិញ្ចើមផ្លូវ។ ដើម្បីអនុលោមតាមច្បាប់ជាតិ និងច្បាប់រដ្ឋ ក្នុងការផ្តល់ភាពស្មើគ្នាសម្រាប់លទ្ធភាពក្នុងការធ្វើដំណើរ និងដើម្បីឲ្យស្របតាមដំណោះស្រាយដែលបានព្រមព្រៀងគ្នាកាលពីឆ្នាំ ២០១៧ មានករណីជាច្រើន ដែលយើងមិនអាចចៀសផុតពីការប្តូរទីតាំងនេះ។